# មេរៀនទី ១១៩: ព្រះយេស៊ូវចម្អែតមនុស្សប្រាំពាន់នាក់

## យ៉ូហាន ៦:១-១៥

**គោលបំណង៖** ព្រះនឹងផ្គត់ផ្គង់សេចក្តីត្រូវការរបស់យើង។

**ខគម្ពីរចងចាំ៖ ភីលីព ៤:៦** *"កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះឲ្យជ្រាបពីសេចក្តីសំណូម របស់អ្នករាល់គ្នា ក្នុងគ្រប់ការទាំងអស់ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរទាំងពោលពាក្យអរព្រះគុណផង។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលយើងមើលទៅហាក់បីដូចជាគ្មានសេចក្តីសង្ឃឹម ព្រះបានមើលឃើញពីឱកាសក្នុងការពង្រឹងសេចក្តីជំនឿរបស់យើង ហើយឲ្យយើងធ្វើនូវកិច្ចការរបស់ទ្រង់បានយ៉ាងល្អ។ ដូចដែលទ្រង់បានធ្វើសម្រាប់ភីលីព ព្រះយេស៊ូវអញ្ជើញយើងឱ្យគិតឱ្យកាន់តែធំ ហើយពិចារណាអំពីរបៀបដែលព្រះអាចធ្វើឱ្យអ្វីដែលមិនអាចទៅរួចឲ្យទៅរួចបាន។ តើអ្វីទៅជា "ហ្វូងមនុស្សដ៏ច្រើនដែលស្រេកឃ្លាន" ក្នុងជីវិតរបស់អ្នកឥឡូវនេះ? តើអ្នកកំពុងជួបបញ្ហាហិរញ្ញវត្ថុមែនទេ? អាពាហ៍ពិពាហ៍? ការងារ? សុខភាព? ចុះបើព្រះយេស៊ូវបានឆ្លើយតបនឹងអ្នកដូចទ្រង់បានធ្វើចំពោះភីលីព ហើយសួរថា "តើអ្នកគួរធ្វើដូចម្តេចដើម្បីបង់វិក្កយបត្ររបស់អ្នកក្នុងខែនេះ?" ជាការពិតណាស់អ្នកនឹងឆ្លើយតបដូចជាភីលីព ជាមួយនឹងបញ្ហាដែលមិនអាចទៅរួច។ ប៉ុន្តែជំនួសឱ្យការភ័យខ្លាច អ្នកគួរបញ្ជូនបញ្ហារបស់អ្នកទៅកាន់ព្រះយេស៊ូវ។ ទុកចិត្តលើទ្រង់ក្នុងការផ្តល់ឱ្យអ្នកនូវអ្វីដែលអ្នកត្រូវការ ហើយប្រហែលជាព្រះអង្គអាចផ្តល់ឱ្យអ្នកកាន់តែច្រើនជាងអ្វីដែលអ្នករំពឹងផងដែរ។

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២. ព្រះអម្ចាស់យើងល្អណាស់ ៣. ព្រះជាម្ចាស់កូនសូមអរគុណទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «មួយ ពីរ បី បួន ទះដៃ»




១. ឲ្យកុមារឈរជារង្វង់

២. ឲ្យកុមារចាប់រាប់លេខ ប៉ុន្តែរៀងរាល់ដល់លេខ៥ និងពហុគុណនៃ៥ ( ៥, ១០,១៥, ២០) ពួកគេត្រូវទះដៃ ជំនួសឲ្យការនិយាយលេខ។

៣. ប្រសិនបើកុមាររាប់លេខ ឬភ្លេចទះដៃ នោះគេត្រូវទទួលពិន័យដែលគ្រូដាក់ឲ្យ (ច្រៀង រាំ ឬក៏ធ្វើអ្វីផ្សេងទៀត)

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាយើងតែងតែបង្កើតកំហុសក៏ដោយ ប៉ុន្តែព្រះគឺមិនដែលបង្កើតកំហុសនោះទេ ហើយទ្រង់តែងតែប្រទាននូវអ្វីដែលយើងត្រូវការ។

### ៤. ការណែនាំមេរៀន

តើអ្នកគិតថាបាយមួយចានអាចចម្អែតបានប៉ុន្មាននាក់? ម្នាក់? ពីរនាក់? ឬក៏បីនាក់? ចុះបើខ្ញុំប្រាប់អ្នកថាខ្ញុំអាចចម្អែតមនុស្សបាន ១០០០នាក់ ដោយប្រើបាយតែមួយចាន? តើអ្នកជឿខ្ញុំដែរឬទេ? ខ្ញុំគឺគ្មានអំណាចក្នុងការធ្វើបែបនេះនោះទេ ប៉ុន្តែនៅទីនោះមានម្នាក់ដែលអាចធ្វើការនោះបាន! ថ្ងៃនេះយើងនឹងរៀនអំពី ព្រះយេស៊ូវដែលទ្រង់អាចចម្អែតមនុស្ស៥,០០០នាក់ដោយប្រើនំប៉័ងម្សៅឱក៥ដុំ និងត្រីតូចតែ២ប៉ុណ្ណោះ ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះ រឿងនៅក្នុងព្រះគម្ពីររបស់យើងដកស្រង់ចេញពីព្រះគម្ពីរយ៉ូហាន។ ថ្ងៃមួយយ៉ូហាន និងសិស្សរបស់ព្រះយេស៊ូវផ្សេងទៀតកំពុងតែនៅជាមួយព្រះយេស៊ូវ។ មនុស្សម្នាគឺពិតជាច្រើនខ្លាំងមែនទែនបានមកជួបជុំគ្នា ដើម្បីចង់ឃើញព្រះយេស៊ូវ ព្រះគម្ពីរបានប្រាប់យើងថាមានមនុស្សច្រើនជាង ៥,០០០នាក់នៅទីនោះ។ វាគឺពិតជាច្រើនខ្លាំងណាស់! ហើយនោះគឺរាប់តែចំនួនមនុស្សប្រុសតែប៉ុណ្ណោះ។ ដូច្នេះប្រសិនបើយើងរាប់ទាំងមនុស្សស្រី និងក្មេងៗទៀតនោះ គឺប្រហែលជាមានជាង ១០,០០០ទៅ១៥,០០០នាក់ឯណ្ណោះ! ពួកគេទាំងនោះចង់ឃើញពីការអស្ចារ្យរបស់ព្រះយេស៊ូវ ពីព្រោះពួកគេបានឮពីការអស្ចារ្យដែលព្រះបានព្យាបាលអ្នកឈឺឲ្យបានជា។

នៅពេលដែលមនុស្សដ៏ច្រើនកុះករនោះឃ្លាន ព្រះយេស៊ូវបានប្រាប់ទៅពួកសិស្សទ្រង់ថា ចូរចំអែតពួកគេទៅ។ ឥឡូវនេះសាកស្រម៉ៃមើលថាបើអ្នកជាសិស្សម្នាក់របស់ព្រះយេស៊ូវដែរនោះ។ តើអ្នកនិងធ្វើរបៀបណាដើម្បីឲ្យអ្នកអាចចម្អែតមនុស្សដ៏ច្រើនកុះករបានទាំងដែលអ្នកគ្មានអាហារ និងមានលុយតែបន្តិចបន្តួចនោះ? ពួកសិស្សគឺមិនអាចរកវិធីសាស្រ្តក្នុងការចម្អែតពួកគេបាននោះទេ។

ប៉ុន្តែនៅពេលនោះក៏មានក្មេងប្រុសម្នាក់បានឲ្យអាហាររបស់ខ្លួនទៅព្រះយេស៊ូវ។ វាគឺជាអាហារដ៏តិចមួយ គឺមានតែនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយប៉ុណ្ណោះ។ វាគឺមិនគ្រប់ទេសម្រាប់មនុស្សដ៏ច្រើននោះ! ប៉ុន្តែព្រះយេស៊ូវបានធ្វើការដ៏អស្ចារ្យមួយ។ ទ្រង់បានយកអាហាររបស់ក្មេងប្រុសនោះ ហើយបានធ្វើការអរព្រះគុណរួចក៏ហុចវាទៅឲ្យពួកសិស្ស និងបានប្រាប់ពួកគេឲ្យចែកអាហារទាំងអស់នោះទៅកាន់អ្នកគ្រប់គ្នា។

ពួកសិស្សក៏ចាប់ផ្តើមចែកអាហារទាំងអស់នោះ។ នៅពេលដែលពួកគេធ្វើការចែកវាក៏មានច្រើនទៀតនៅក្នុងកន្ត្រកសម្រាប់ចែកបន្ត! មនុស្សគ្រប់គ្នាមានការភ្ញាក់ផ្អើលជាខ្លាំង មិនត្រឹមតែគ្រប់សម្រាប់គ្រប់គ្នាហូបនោះទេ គឺមានច្រើនជាងអ្វីដែលពួកគេបានគិតទៅទៀត វាគឺនៅសល់រហូតដល់ទៅ ១២កន្ត្រកឯណ្ណោះ!

ព្រះយេស៊ូវអាចធ្វើឲ្យរបស់តិចមួយទៅជារបស់ច្រើនបាន! ព្រះចង់ផ្គត់ផ្គង់គ្រប់ទាំងរបស់ដែលអ្នកត្រូវការ ដូចជាអ្វីដែលទ្រង់បានយកចិត្តទុកដាក់ចំពោះមនុស្សដែលឃ្លានទាំងអស់នោះដែរ។ ព្រះអង្គអាចធ្វើបានគ្រប់ការទាំង-អស់! អ្នកអាចប្រាប់ព្រះបានពីតម្រូវការរបស់អ្នក ហើយទ្រង់នឹងផ្គត់ផ្គង់សម្រាប់អ្នក។ អ្នកអាចធ្វើការទាំងអស់នេះបានតាមរយៈការអធិស្ឋាន។ ការអធិស្ឋានគឺជារឿងដ៏សាមញ្ញបំផុតក្នុងការនិយាយទៅកាន់ព្រះ។ ទ្រង់ជ្រាបដឹងថាយើងចង់និយាយពីអ្វី ទោះបីជាពេលខ្លះយើងមានបញ្ហាក្នុងការនិយាយប្រាប់ទ្រង់ក៏ដោយ។ បើទោះបីជាពេលខ្លះយើងនិយាយត្រឹមតែមួយពាក្យក៏ដោយ តែទ្រង់នឹងជ្រាបដឹងពីការនោះ។ នេះក៏ព្រោះតែទ្រង់ជ្រាបដឹងពីអ្វីដែលយើងបានគិតនិងពីអារម្មណ៍របស់យើងផងដែរ។

## ៦. សំនួរពិភាក្សា

១. តើមានមនុស្សប៉ុន្មាននាក់បានមកជួបជុំគ្នាដើម្បីឮពីព្រះយេស៊ូវ? *ច្រើនជាង ៥,០០០នាក់*

២. តើព្រះយេស៊ូវចង់ធ្វើអ្វីសម្រាប់មនុស្សដ៏ច្រើនទាំងអស់នោះ? *ចម្អែតពួកគេ*

៣. តើក្មេងប្រុសបានឲ្យអ្វីទៅព្រះយេស៊ូវ? *នំបុ័ងប្រាំដុំ និងត្រី២កន្ទុយ*

៤. តើព្រះបានចម្អែតមនុស្សប៉ុន្មាននាក់តាមរយៈនំបុ័ងប្រាំដុំនិងត្រី២កន្ទុយនេះ? *ច្រើនជាង ៥,០០០នាក់*

៥. តើអ្នកត្រូវការអ្វីពីព្រះយេស៊ូវតឡូវនេះ? *ទុកឲ្យកុមារជាអ្នកឆ្លើយ និងអធិស្ឋានសម្រាប់ពួកគេ*

## ៧. ល្បែងកំសាន្ត « ផ្លាស់ទីក្រដាស»




**សម្ភារៈដែលត្រូវការ៖** ក្រដាសតូចៗ ទុយោទឹក, ចាន, កៅអី និងតុវែង

១. ចែកកុមារជា ២ ឬ ៤ក្រុម។

២. ដាក់ក្រដាសតូចៗនៅក្នុងចានក្រដាស ហើយដាក់វានៅលើកៅអីនៅពីមុខក្រុមនីមួយៗ។ ឲ្យទុយោទៅកុមារម្នាក់មួយ។ ដាក់តុនៅចម្ងាយ ១ម៉ែត្រពីកៅអី ហើយដាក់ចានទទេ២នៅលើតុនោះ។



៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារដែលនៅមុខគេត្រូវបឺតក្រដាស (ដោយប្រើដង្ហើមបឺតក្រដាស) ហើយយកវាទៅដាក់នៅក្នុងចានទទេ ដែលនៅលើតុនោះ។ បន្ទាប់កុមារត្រូវរត់មកកាន់ក្រុមរបស់គេវិញ ហើយប៉ះកុមារទី២ ដើម្បីបន្តលេងល្បែងនេះ។ ប្រើពេលលេងល្បែងនេះ២នាទី។ ហើយក្រុមណាដែលអាចជញ្ជូនក្រដាសដាក់ក្នុងចានបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាការដែលពួកគេជញ្ជូនក្រដាសដាក់ចូលទៅក្នុងចានទទេបានអីចឹង ព្រះយេស៊ូវអាចធ្វើការដ៏ធំចេញពីការដ៏តូចបាន។ នៅពេលដែលយើងមានព្រះយេស៊ូវ គឺយើងមានអ្វីៗគ្រប់យ៉ាង ពីព្រោះព្រះយេស៊ូវតែងតែផ្គត់ផ្គង់សេចក្តីត្រូវការរបស់យើង។

## ៨. ខគម្ពីរចងចាំ ភីលីព ៤:៦

## ៩. ហត្ថកម្ម «ព្រះនឹងផ្គត់ផ្គង់គ្រប់ទាំងសេចក្តីត្រូវការរបស់យើង»



**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហាត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ផាត់ពណ៌រូបកន្ត្រក រូបត្រី និងរូបនំបុ័ង

២. កាត់រូបកន្ត្រក រូបត្រី និងរូបនំបុ័ងនោះចេញមក

៣. បត់រូបកន្ត្រកនោះពាក់កណ្តាល ហើយបិតវា។ (សូមកុំបិតត្រង់ដៃរបស់កន្ត្រក ដើម្បីទុកវាឲ្យនៅបើក)

៤. ដាក់រូបត្រីនិងរូបនំបុ័ងចូកក្នុងកន្ត្រកនោះ ហើយឲ្យកុមារនិយាយថា“ព្រះនឹងផ្គត់ផ្គង់សេចក្តីត្រូវការរបស់យើង”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះនឹងផ្គត់ផ្គង់គ្រប់ទាំងសេចក្ដីត្រូវការរបស់យើង







